# ៣ - ទីស្ដីការរដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សេចក្ដីសម្រេច

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៦

## សេចក្ដីសម្រេច ០៣៨ សសរ.កសក

## ស្ដីពីការបង្កើតគណៈកម្មការអនុវត្តគំរោងកម្មវិធី KRII ដែលជាជំនួយរបស់រាជរដ្ឋាភិបាលជប៉ុន

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៨ ស្ដីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញកិច្ចព្រមព្រៀង ស្ដីពីជំនួយរបស់ជប៉ុន ដើម្បីគំរោងការបង្កើនផលិតផលស្បៀងនៅកម្ពុជា ដែលបានចុះហត្ថលេខារវាង ឯកឧត្ដម ហោ ណាំហុង រដ្ឋមន្ត្រីការបរទេស សមាជិកក្រុមប្រឹក្សា ជាតិជាន់ខ្ពស់កម្ពុជា និង ឯកឧត្ដម យ៉ូស៊ីអាគីហាតា ប្រធានបេសកកម្ម JICA ជប៉ុន កាលពីថ្ងៃទី១៧ ខែ មិថុនា ១៩៩២
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការអនុវត្តគំរោង KRII មួយដែលមានសមាសភាពដូចខាងក្រោម :

១–លោក **ឡៅ នី** ប្រធាននាយកដ្ឋានផែនការ–ស្ថិតិ ប្រធាន

២–លោក **ឈួន គឹមឆោ** ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ អនុប្រធាន

៣–លោក **ជ័យ សាវឌ្ឍ** ប្រធានក្រុមហ៊ុនសំភារៈកសិកម្ម សមាជិក

៤–លោក **មាស់ សុខ** អនុប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ សមាជិក

៥–លោក **សាន ទន្តន្ទី** មន្ត្រីផែនការស្ថិតិ សមាជិករាយការណ៍

៦–លោក **ទិត្យ សុំម៉ឺន** មន្ត្រីផែនការស្ថិតិ សមាជិក រាយការណ៍

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ចធ្វើការបែងចែកតាមដាន និង ត្រួតពិនិត្យការប្រើប្រាស់សំភារៈកសិកម្ម នៃគំរោង KRII ធ្វើការវាយតំលៃ និងធ្វើរបាយ-ការណ៍លើ នៃការអនុវត្តន៍គំរោងនេះជាប្រចាំ ។

**ប្រការ ៣** : អគ្គនាយកក្រសួង ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ ប្រធានក្រុមហ៊ុនសំភារៈកសិកម្ម និង សាមីជនដូចមានក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តី សំរេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**ឈា សុខ**

* * *